


# អ្នកជាអ្នកកំណត់វាសនាសហគមន៍របស់អ្នក

រៀងរាល់ដប់ឆ្នាំម្តង ក្រោយពីជំរឿនសហរដ្ឋអាមេរិក រដ្ឋកាលីហ្វ័រញ៉ាត្រូវគូសព្រំដែនមណ្ឌលសភា មណ្ឌលព្រឹទ្ធសភាតំណាងរដ្ឋ មណ្ឌលសភាតំណាងរដ្ឋ និងមណ្ឌលគណៈកម្មការសមភាពរបស់រដ្ឋសាជាថ្មី ដើម្បីឆ្លុះបញ្ចាំងពីទិន្នន័យប្រជាជនថ្មី។ ច្បាប់ស្តីពីការបោះឆ្នោត Voters FIRST Act ផ្តល់អំណាចដល់ពលរដ្ឋកាលីហ្វ័រញ៉ា ដោយធានាថាមណ្ឌលបោះឆ្នោតថ្មី និងត្រឹមត្រូវ ត្រូវបានបែងចែកដោយគ្មានពាក់ព័ន្ធនឹងផលប្រយោជន៍ពិសេសនយោបាយ ឬឥទ្ធិពលនយោបាយឡើយ។

គណៈកម្មការកំណត់បែងចែកមណ្ឌលបោះឆ្នោតសម្រាប់ពលរដ្ឋកាលីហ្វ័រញ៉ា នឹងបើកកិច្ចប្រជុំជាសាធាណារណៈ និងទទួលយកមតិយោបល់ជាសាធារណៈ។ នេះគឺជាឱកាសសម្រាប់អ្នកក្នុងការក្លាយជាផ្នែកមួយនៃការបង្កើតព្រំដែនមណ្ឌលដែលត្រឹមត្រូវ និងមានតម្លាភាពដែលបម្រើដល់ឧត្តមប្រយោជន៍របស់ពលរដ្ឋកាលីហ្វ័រញ៉ា។ នៅក្នុងឆ្នាំ2021 គណៈកម្មការនេះនឹងបំពេញកិច្ចការដើម្បីបង្កើត និងអនុម័តផែនទីមណ្ឌល នៅមុនពេលផែនទីចុងក្រោយ ត្រូវបានបញ្ជាក់ជូនមន្ត្រីកិច្ចការរដ្ឋបាលរដ្ឋកាលីហ្វ័រញ៉ា។

## វិធីចូលរួម

**ក្នុងអំឡុងពេលកិច្ចប្រជុំជាសាធារណៈ៖**

នៅក្នុងរដូវរងា និងរដូវក្តៅឆ្នាំ2021 គណៈកម្មការនេះ នឹងបើកកិច្ចប្រជុំជាច្រើន ដែលអ្នកអាចផ្តល់មតិចូលរួមបាន តាមរយៈទូរសព្ទក្នុងអំឡុងពេលកិច្ចប្រជុំ ឬតាមប្រព័ន្ធអេឡិចត្រូនិក នៅមុនពេលកិច្ចប្រជុំនោះ។ អ្នកអាចស្វែងយល់បន្ថែមអំពីកិច្ចប្រជុំផ្តល់យោបល់ក្នុងសហគមន៍នៅពេលខាងមុខ ដោយចូលទៅមើលគេហទំព័ររបស់យើងនៅ៖ www.WeDrawTheLinesCA.org។

**តាមប្រព័ន្ធអេឡិចត្រូនិក៖**

អ្នកក៏អាចផ្តល់ការចូលរួមបានផងដែរទៅគណៈកម្មការនេះដោយអ៊ីម៉ែលទៅ៖ VotersFirstAct@crc.ca.gov ឬដោយគូសផែនទីរបស់អ្នកដោយប្រើឧបករណ៍ "គូសផែនទីសហគមន៍ខ្ញុំ" (Draw My Community) និងប្រគល់ផែនទីនោះទៅកាន់គណៈកម្មការនេះ ដោយចូលទៅកាន់៖ DrawMyCACommunity.org។

**ជាលាយលក្ខណ៍អក្សរ៖**

អ្នកអាចផ្ញើឯកសារជាក្រដាសស្នាមតាមប្រៃសណីយ៍ទៅកាន់៖
California Citizens Redistricting Commission, 721 Capitol Mall, Suite 260, Sacramento, CA 95814

**យើងសូមលើកទឹកចិត្តឲ្យអ្នកចូលទៅមើលគេហទំព័រ និងឆាណែលបណ្តាញសារព័ត៌មានសង្គមជាប្រចាំសម្រាប់ព័ត៌មានបច្ចុប្បន្នភាពថ្មីៗ។**

California Citizens Redistricting Commission
721 Capitol Mall, Suite 260, Sacramento, CA 95814
(916) 323-0323 -- WeDrawTheLinesCA.org
@WeDrawTheLinesCA